**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៣៩១
ចុះថ្ងៃទី០៨-៨-២០០៨

**សាលដីកា**
លេខ: ៨០ ក្រ.ពញ
ចុះថ្ងៃទី២០-៨-២០១០

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំ និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណ: នៅសាលាឧទ្ធរណ៍នា ថ្ងៃទី២០-៨-២០១០ ម៉ោង១៨:០០រសៀល ដោយមានសមាសភាពដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៣៩១ ចុះថ្ងៃទី០៨-៨-២០០០៨រវាង:

**<u>-ជនជាប់ចោទ:</u>**

១-ឈ្មោះ [redacted]រី ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិសំបួរ ឃុំអង្គតាសេ ស្រុកមេសាង ខេត្តព្រៃវែង មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសមុនគ្មាន ។

២-ឈ្មោះ [redacted]រី ហៅ ម៉ាប់ ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ។

៣-ឈ្មោះ [redacted] សាវៃន ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ ។

៤-ឈ្មោះ [redacted]ថា ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ។

៥-ឈ្មោះ [redacted]ពៅ ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ។

៦-ឈ្មោះ [redacted]រុន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ។

ត្រូវចោទពីបទ: ឃាតកម្មគិតទុកជាមុន និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិវាល ឃុំក្តាញ ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃទី០៨-៩-២០០៨បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ស៊-






CamScanner

៧-ឈ្មោះ [redacted]ចន្ទី ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ ។

៨-ឈ្មោះ [redacted]រី ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ។

ត្រូវចោទពីបទៈ សមគំនិតឃាតកម្មគិតទុកជាមុន និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសំរោង ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃទី០៨-៩-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៤, ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៩-ឈ្មោះ [redacted]សៀន ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ ។

ត្រូវចោទពីបទៈ ប្រើប្រាស់ កាន់កាប់ រក្សាអាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសំរោង ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីខែកុម្ភៈ ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៤, ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ម៉េង ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

## **<u>ឯរឿងហេតុមានដូចតទៅ</u>**

តាមពាក្យបណ្តឹងចុះថ្ងៃទី០៩-៩-២០០៤ របស់ឈ្មោះ [redacted] ម៉េង ប្តឹងពីក្រុមចោរប្លន់ប្រដាប់អាវុធចំនួន៥នាក់ ពុំស្គាល់ឈ្មោះ ដែលប្លន់នៅផ្ទះរបស់ខ្លួន និង បាញ់សម្លាប់ប្រពន្ធខ្លួន ដោយសំអាងហេតុថាៈ កាលពីថ្ងៃទី០៩-៩-២០០៤ វេលាម៉ោង១យប់ ក្រុមចោរប្លន់ប្រដាប់អាវុធមានគ្នា៥នាក់ អាវុធ៣ដើម កាំភ្លើងវែងអាកាមួយដើម និងអាវុធខ្លីពីរដើម បានប្លន់ផ្ទះខ្លួនយកសំភារៈអស់ប្រាក់១៧០០ដុល្លាអាមេរិក លុយខ្មែរមួយលានរៀល មាស២តម្លឹង ទូរស័ព្ទដៃ២គ្រឿង និង រើសហូលអស់ជាង១០ក្បិន ពួកក្រុមចោរប្លន់បានធ្វើសកម្មភាព បណ្តាលឲ្យស្លាប់ប្រពន្ធខ្លួន និង របួសកូនប្រុស២នាក់ ព្រមទាំងរូបខ្លួន ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៤៥ "គ" ចុះថ្ងៃទី២៥-១០-២០០៥ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោមៈ

I-ផ្តន្ទាទោសជនជាប់ចោទៈ

១-ឈ្មោះ [redacted] រី ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់២០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

២-ឈ្មោះ [redacted]ពៅ ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារកំណត់២០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

៣-ឈ្មោះ [redacted]សាវៃន ភេទប្រុស អាយុ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន។

៤-ឈ្មោះ [redacted] ថា ភេទប្រុស អាយុ៣៤ឆ្នាំ ដាក់ពន្ធនាគារកំណត់១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

៥-ឈ្មោះ [redacted]រុន ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

៦-ឈ្មោះ [redacted] រី ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់២០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

ពីបទៈ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃទី០៨-៩-២០០៤ តាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៧-ឈ្មោះ [redacted]ចន្ទី ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន។

៨-ឈ្មោះ [redacted] រី ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន។

ពីបទៈ សមគំនិតឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃទី០៨-៩-២០០៤ តាមបញ្ញត្តិមាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ស



៥៤

CamScanner

II-ផ្តន្ទាទោសជនជាប់ចោទ:

១-ឈ្មោះ: [redacted] វី ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

២-ឈ្មោះ: [redacted] ពៅ ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៣-ឈ្មោះ: [redacted] សាវ៉ន ភេទប្រុស អាយុ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៤-ឈ្មោះ: [redacted] ថា ភេទប្រុស អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៥-ឈ្មោះ: [redacted] វុន ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៦-ឈ្មោះ: [redacted] វី ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៧-ឈ្មោះ: [redacted] ចន្ទី ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

៨-ឈ្មោះ: [redacted] វី ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃអនុវត្តទណ្ឌកម្មទី១ចប់ ។

ពីបទ: ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិភល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃទី០៨-៩-២០០៤ តាមបញ្ញត្តិមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៩-ឈ្មោះ: [redacted] សៀន ភេទប្រុស អាយុ៤១ឆ្នាំ ដាក់ពន្ធនាគារកំណត់១ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ពីបទ: រក្សាទុកអាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសំពេង ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីខែកុម្ភៈ ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

III-បង្គាប់ឲ្យឈ្មោះ: [redacted] វី, [redacted] សាវ៉ន, [redacted] ថា, [redacted] ពៅ, [redacted] វុន, [redacted] វី, [redacted] ចន្ទី និង [redacted] វី រួមគ្នាសងជួសជុលការខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ តាមចំណែកស្មើៗគ្នាឲ្យទៅជនរងគ្រោះឈ្មោះ: [redacted] ម៉េង មាន៖

- ប្រាក់ដុល្លា ចំនួន ១៧,០០០$ (មួយម៉ឺនប្រាំពីរពាន់ដុល្លា)
- លុយខ្មែរ ចំនួន ១,០០០,០០០៛ (មួយលានរៀល)
- មាស ចំនួន ២០តម្លឹង (ម្ភៃតម្លឹងមាស)
- ជញ្ជៀនពេជ្រមួយវង់ ស្មើ៨៨០$ (ប្រាំបីរយប៉ែតសិបដុល្លា)
- សំពត់ហូល ១០ក្បិន ។

IV-វត្ថុតាងមាន:

- អាវុធAK ៣ដើម គ្រាប់១០០គ្រាប់ ។
- បង់AK ៤បង់

សំរេចរឹបអូសជាសម្បត្តិរដ្ឋ ។

- ដែកដាប់២, គន្លឹះសោស្វែងក្របី២, ប្រអប់ទឹកដោះគោនៅ២, ស្បែកជើងសិក១ចំហៀង និងឡាំងដែក១ សំរេចរឹបអូសបំផ្លាញចោល ។

សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨-១០-២០០៥ នៅចំពោះមុខជនជាប់ចោទ៨នាក់ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រី និងជនរងគ្រោះ [redacted] ម៉េង បើកផ្លូវប្តឹងទាស់១៥ថ្ងៃ និង៦០ថ្ងៃទៀត សំរាប់ប្តឹងឧទ្ធរណ៍ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រមនេះ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៥០ "គ" ចុះថ្ងៃទី១៤-៧-២០០៨ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១-តម្កល់សាលក្រមព្រហ្មទណ្ឌ លេខៈ៨៥ "គ" ចុះថ្ងៃទី២៥-១០-២០០៥ របស់សាលាដំបូងខេត្តតាកែវ ត្រង់ចំណុចទី៦តូច ក្នុងចំណុចទីI និងទីII និងត្រង់ចំណុចទីIII ទុកនៅដដែល ។

២-សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខកូនក្តីបើកផ្លូវប្តឹងតវ៉ាតាមច្បាប់ ។

-បានឃើញ របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី១៦-០២-២០០៩ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី០១-០៨-២០០៩។

## នាពេលសវនាការ

-ជនជាប់ចោទ ឈ្មោះ [redacted] រី (អវត្តមាន)

-មេធាវី លោក [redacted] ស៊ីថាន (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ម៉េង (អវត្តមាន)

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ [redacted] រី ដូច្នេះនៅពេលនេះ ខ្លួនសុំឲ្យសាលាឧទ្ធរណ៍ តម្កល់សាលក្រមរបស់សាលាដំបូងខេត្តតាកែវ ដដែល ។

-មេធាវី [redacted] ស៊ីថាន ការពារឲ្យជនជាប់ចោទលើកឡើងថាៈ នៅពេលនេះ ខ្លួនសុំជំទាស់នឹងសាលក្រមព្រហ្មទណ្ឌ ដោយហេតុថា កូនក្តីខ្លួនអត់បានប្រព្រឹត្ត ដូចការចោទប្រកាន់ទេ ពីព្រោះកូនក្តីខ្លួនជាអ្នករត់ម៉ូតូឌុប មិនបានដឹងពីសកម្មភាពអ្វីទាំងអស់ ហើយម្យ៉ាងវិញទៀតក៏គ្មានសាក្សី ឬភស្តុតាងណាមួយបញ្ជាក់ច្បាស់ថា កូនក្តីខ្លួនបានប្រព្រឹត្តទេ។ ដូច្នេះ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍សម្រេចដោះលែងកូនក្តីខ្លួន និងសុំឲ្យសម្រេចលើកលែងការចោទប្រកាន់កូនក្តីខ្លួនតាមច្បាប់ ។

-ក្រោយពីបានឃើញចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-៧-២០០៨ របស់ឈ្មោះ [redacted] រី ប្តឹងឧទ្ធរណ៍នឹងសាលក្រម លេខៈ ៥០"គ" ចុះថ្ងៃទី១៤-៧-២០០៨ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ W.



CamScanner

២-ជនជាប់ចោទឈ្មោះ[redacted] ថា, [redacted]រី, [redacted]រី, [redacted] សារ៉ែន និងឈ្មោះ[redacted]រុន បានឆ្លើយសារភាពនៅមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការដ្ឋាននគរបាលខេត្តតាកែវថា: កាលពីថ្ងៃទី០៨-៩-២០០៤ ពួកខ្លួនពិតជាបានប្លន់ផ្ទះអ្នករកស៊ីហួលជាមួង ដែលស្ថិតនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រាកដមែន។ ក្នុងការប្លន់នេះ ពួកខ្លួនមានគ្នាប្រាំមួយនាក់ គឺមានឈ្មោះ [redacted] រី, [redacted] ថា, [redacted] រី, [redacted] ពៅ, [redacted] សារ៉ែន និងឈ្មោះ[redacted]រុន ដោយឈ្មោះ[redacted] ចន្ទី និងឈ្មោះ[redacted]រី ជាអ្នកចង្អុលបង្ហាញផ្ទះជនរងគ្រោះ ដែលជាចំណុចគ្រោងប្លន់ រួចនាំក្រុមជនជាប់ចោទដើរមើលភូមិសាស្ត្រ។ ប៉ុន្តែនៅដំណាក់កាលនៃតុលាការ ជនជាប់ចោទទាំងអស់បានឆ្លើយបដិសេធ ថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ តែចម្លើយបដិសេធនេះ ពុំមានភស្តុតាងអ្វី ដែលនាំឲ្យតុលាការបដិសេធចម្លើយនៅនគរបាលដែរ ដែលគ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវតែប៉ុណ្ណោះ ។

៣-ក្នុងពេលធ្វើសកម្មភាពប្លន់សំលាប់ ជនជាប់ចោទបានប្រើប្រាស់អាវុធអាការ ចំនួន៣ដើម ដោយបាញ់ប្រហារទៅលើជនរងគ្រោះយ៉ាងសាហាវ បណ្តាលឲ្យជនរងគ្រោះឈ្មោះ [redacted]ខេង ស្លាប់ និងកូន២នាក់រងរបួស។ សំភារៈ ដែលជនជាប់ចោទប្លន់ បានរួមមានប្រាក់១៧០០០$, ១.០០០.០០០៛, មាស២០តម្លឹង, ទូរស័ព្ទដៃ២គ្រឿង និងហួលល្អៗជាង១០ក្បិន ។

៤-តាមការយល់ឃើញខាងលើ និង ភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]រី, [redacted]រី, [redacted] សារ៉ែន, [redacted] ពៅ, [redacted] ថា និង[redacted]រុន ពីបទ: មនុស្សឃាតគិតទុកជាមុន និង ប្រើប្រាស់អាវុធខុសច្បាប់ និងឈ្មោះ[redacted] ចន្ទី ពីបទ: សមគំនិតក្នុងអំពើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីថ្ងៃ០៨-៩-២០០៤ តាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ, មាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និង គ្រាប់រំសេវ ។

៥-រឿងក្តីនេះ ត្រូវបានសាលាដំបូងខេត្តតាកែវ ធ្វើការអង្កេត និង លើកយកសំអាងហេតុ មកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់លើកយកសំអាងហេតុនោះមកបញ្ជាក់ជាថ្មីទៀតទេ ។

៦-សាលក្រមព្រហ្មទណ្ឌ លេខ: ៨៥"គ" ចុះថ្ងៃទី២៥-១០-២០០៥ និងលេខ: ៥០"គ" ចុះថ្ងៃទី១៩-៧-២០០៨ របស់សាលាដំបូងខេត្តតាកែវ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-៧-២០០៨ របស់ឈ្មោះ [redacted] រី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៨៥"គ" ចុះថ្ងៃទី២៥-១០-២០០៥ និងលេខ: ៥០"គ" ចុះថ្ងៃទី១៩-៧-២០០៨ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ[redacted]រី។